# ស្ថានីយបុរាណជើងឯក៖ ធនធានវប្បធម៌ដ៏កម្រសម្រាប់បេតិកភណ្ឌជាតិនៃកម្ពុជា

ជើងឯកជាឈ្មោះភូមិផង និងជាឈ្មោះសង្កាត់ផង(ភូមិជើងឯក, សង្កាត់ជើងឯក) ក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ ស្ថិតនៅភាគខាងត្បូងនៃចំណុចកណ្តាលរាជធានីភ្នំពេញ មានចម្ងាយប្រមាណ១០គីឡូម៉ែត្រពីវិមានឯករាជ។

នៅឆ្នាំ២០០០ លោក ផុន កសិកា ព្រមទាំងអតីតនិស្សិតបុរាណវិទ្យានៃមហាវិទ្យាបុរាណវិទ្យា ជំនាន់ទី៩ គឺលោក ឆាយ វិសុទ្ធ (បច្ចុប្បន្នគឺជាប្រធាននាយកដ្ឋានសារមន្ទីរជាតិនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ) បានរកឃើញ និងអាចកំណត់យ៉ាងច្បាស់លាស់ថា ជើងឯកមានស្ថានីយបុរាណមួយក្នុងចំណោមស្ថានីយបុរាណរាប់ពាន់ទៀតក្នុងប្រទេសកម្ពុជា។ ស្ថានីយជើងឯកជាមជ្ឈមណ្ឌលផលិតកុលាលភាជន៍ដ៏ធំមួយក្នុងប្រទេសកម្ពុជា ដែលចាប់ផ្តើមផលិតកុលាលភាជន៍តាំងពីសតវត្សរ៍ទី៥ រហូតដល់សតវត្សរ៍ទី១៣ នៃគ្រិស្តសករាជ ហើយការផលិតកុលាលភាជន៍នេះប្រព្រឹត្តទៅដោយការដុតក្នុងឡមិនមែនដុតនៅទីវាលទេ។

កាលពីឆ្នាំ២០០០កន្លងទៅ ជើងឯកជាតំបន់ព្រៃស្ដុក ព្រៃលិចទឹកនៅរដូវវស្សា និងជាតំបន់លិចទឹកដោយនៅតាមកន្ទែងខ្លះជាប់មាត់បឹង ហើយក៏ស្ថិតនៅជាប់មាត់បឹងធំមួយមានឈ្មោះថា «បឹងជើងឯក» ក៏ប៉ុន្តែមិនគួរឱ្យជឿសោះថា តំបន់ជើងឯកបន្សល់ទុកនូវបុរាណវត្ថុ និងបុរាណវត្ថុអចល័ត (ជាសំណង់ប្រាសាទ រចនាសម្ព័ន្ធឡ និងភូមិ ឬជាប្រព័ន្ធធារាសាស្ត្រដែលនៅជាប់នឹងដី) ជាច្រើនសម្រាប់អ្នកសិក្សាស្រាវជ្រាវសិក្សាស្វែងយល់អំពីបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។

បេតិកភណ្ឌវប្បធម៌ដែលរកឃើញមានដូចជា សិលាចារឹក, លិង្គព្រះឥសូរ, គ្រឿងបង្គុំសំណង់ប្រាសាទ (ដូចជា សរសេរពេជ្រ, ផ្តែរ, មេទ្វារ, ថ្មទ្រនាប់ជណ្តើរ, ជើងទម្រ), ទួលប្រាសាទ(ជាសំណង់ប្រាសាទសង់ពីឥដ្ឋនៅសម័យហ្វូណន), ភូមិមូល ព្រមទាំងទួលឡដុតកុលាលភាជន៍ជាច្រើនទៀត។ នៅតាមទួលឡដុតកុលាលភាជន៍

អត្ថបទដោយ៖ **លោក ផុន កសិកា**

ក៏មានបំណែកកុលាលភាជន៍រាយប៉ាយជាច្រើន។ បំណែកកុលាលភាជន៍ជាប្រភេទកុលាលភាជន៍ផុយផង និងប្រភេទកុលាលភាជន៍រឹងផង ដែលមានលាបស្រទាប់រលោងពណ៌ត្នោតបៃតង និងពណ៌សំបកមង្ឃុត។ ឆ្នាំក្រោយៗមកទៀត លោកផុន កសិកា បានបន្តសិក្សាស្រាវជ្រាវនៅស្ថានីយជើងឯក ហើយបានរកឃើញទិន្នន័យជាច្រើន ដែលនឹងរៀបរាប់បង្ហាញនៅអត្ថបទក្រោយៗទៀត។




ទីតាំងស្ថានីយបុរាណជើងឯកមើលពីលើអាកាស



ទីតាំងទួលបុរាណដែលដើមឈើដុះពីលើក្នុងស្ថានីយបុរាណជើងឯក

អត្ថបទដោយ៖ **លោក ផុន កសិកា**



ផ្ទាំងសិលាចារឹក



លិង្គព្រះឥសូរ



ផ្តែរ



កុលាលភាជន៍រកឃើញក្នុងស្ថានីយបុរាណជើងឯក

អត្ថបទដោយ៖ លោក ផុន កសិកា